# សេចក្តីថ្លែងការណ៍របស់លោក គ្រីស្តូហ្វ ប៉េស៊ូ តំណាងឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ថ្លែងបន្ទាប់ពីការបញ្ជូនជនជាតិអ៊ុយហ្គ័រ(Uighurs) ២២នាក់ ចេញពីប្រទេសកម្ពុជា ទៅប្រទេសចិនវិញ

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩

"ក្នុងនាមជាតំណាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ហើយក៏ជាបុគ្គលម្នាក់ ដែលប្រកាន់យ៉ាងមុតមាំចំពោះគោលការណ៍នៃការការពារជាអន្តរជាតិ ដល់អ្នកសុំសិទ្ធិជ្រកកោនពីការធ្វើទុក្ខបុកម្នេញ ខ្ញុំមានការស្រងាកចិត្តជាខ្លាំង។ អ្នកណាក៏អាចក្លាយជាជនភៀសខ្លួនបានដែរ នៅក្នុងពិភពលោកសព្វថ្ងៃនេះ ហើយក៏អាចស្វែងរកការការពារជាអន្តរជាតិបានដែរ ក្រោមច្បាប់អន្តរជាតិស្តីពីជនភៀសខ្លួន។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១ និងមានកាតព្វកិច្ចតាមផ្លូវច្បាប់ ពិនិត្យការស្នើសុំសិទ្ធិជ្រកកោនរបស់បុគ្គលទាំង ២០រូបនេះ និងសំរេចយ៉ាងត្រឹមត្រូវ អំពីឋានៈរបស់ពួកគេ។ រហូតមកទល់ចុងសប្តាហ៍នេះ កម្ពុជាជាកន្លែងជ្រកកោនមួយដ៏មានសុវត្ថិភាពសំរាប់បុគ្គលដែលត្រូវគេធ្វើទុក្ខបុកម្នេញ និងបានអនុវត្តគោលនយោបាយមួយប្រកបដោយមនុស្សធម៌ និងសប្បុរសធម៌។ បីទោះជាអាជ្ញាធរ បានផ្តល់ការធានាយ៉ាងមុតមាំពីដំបូងទីមកថា អាជ្ញាធរបានពិចារណាអំពីបុគ្គលដែលបានសុំសិទ្ធិជ្រកកោនទាំងនេះ ហើយថាអាជ្ញាធរនឹងបំពេញដំណើរការសំរេចអំពីឋានៈជនភៀសខ្លួនរបស់បុគ្គលទាំង ២០នាក់នេះ ប៉ុន្តែភ្លាមៗនោះ ត្រូវបានផ្លាស់ប្តូរទាំងស្រុង កាលពីចុងសប្តាហ៍នេះ នៅពេលដែលវាច្បាស់ណាស់ថា ការផ្លាស់ប្តូរភ្លាមៗនេះ ស្ថិតក្រោមសម្ពាធនោះ ហើយនេះជាលើកដំបូង ដែលអ្នកសុំសិទ្ធិជ្រកកោន ត្រូវបានចាត់ថា ជាជនអន្តោប្រវេសន៍ខុសច្បាប់។

កម្ពុជាក៏ជាភាគីមួយនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ។ អនុសញ្ញាទាំងពីរនេះ គូសបញ្ជាក់ឡើងវិញ ពីគោលការណ៍ជាមូលដ្ឋាននៃអនុសញ្ញាស្តីពីជនភៀសខ្លួន ពី "ការមិនបញ្ជូនត្រឡប់វិញ" ដោយហេតុនេះ គ្មាននរណាម្នាក់ ត្រូវបានគេបញ្ជូនត្រឡប់វិញដោយបង្ខំ ទៅកាន់កន្លែងមួយ ដែលគាត់អាចនឹងត្រូវគេធ្វើទារុណកម្មតាមផ្លូវតុលាការ ឬតាមផ្លូវផ្សេងទៀតឡើយ។ នេះជាគោលការណ៍សំខាន់មួយនៃការការពារជាអន្តរជាតិ

ដែលបានផ្តល់សិទ្ធិជ្រកកោនមានសុវត្ថិភាព ការពារប្រឆាំងនឹងការធ្វើទារុណកម្ម ហើយគោលការណ៍នេះ បានជួយសង្គ្រោះជីវិតជនភៀសខ្លួនរាប់រយពាន់នាក់នៅទូទាំងពិភពលោក។ ហានិភ័យទាំងនេះ គួរតែត្រូវបានធ្វើការវាយតំលៃឲ្យបានត្រឹមត្រូវ និងដោយសត្យានុម័ត នៅមុនការសំរេចណាមួយអំពីបុគ្គលទាំងនេះ។

ការបញ្ជូនត្រឡប់វិញនេះ នាំឲ្យមានកង្វល់រិតតែខ្លាំងឡើងថែមទៀត នៅក្នុងប្រទេសមួយដែលគេដឹងថាមានការធ្វើទុក្ខបុកម្នេញខ្លាំង នៅក្នុងអំឡុងពេលសង្គ្រាម និងនៅក្នុងរបបខ្មែរក្រហម ហើយដែលគេដឹងយ៉ាងច្បាស់បំផុតអំពីតំលៃ និងភាពសំខាន់ចាំបាច់នៃការការពារជនភៀសខ្លួន។ ប្រជាជនកម្ពុជារាប់ពាន់នាក់ ត្រូវបានសង្គ្រោះជីវិត ហើយអរគុណដល់ប្រព័ន្ធការពារជនភៀសខ្លួនជាអន្តរជាតិនេះ រួមទាំងអ្នកដឹកនាំជាច្រើនរូបនៃប្រទេសនេះផងដែរ នៅក្នុងអតីតកាល និងនៅក្នុងពេលបច្ចុប្បន្ននេះ។

ភាពគួរជឿបាន និងភាពអាចពឹងផ្អែកបាននៃប្រព័ន្ធការពារជនភៀសខ្លួន ដែលបានកសាងដោយអត់ធ្មត់នៅកម្ពុជា ដោយមានការជួយឧបត្ថម្ភគាំទ្រយ៉ាងច្រើនពីអង្គការជនភៀសខ្លួន(UNHCR) នោះ បច្ចុប្បន្ននេះកំពុងត្រូវបានចោទជាបញ្ហាធ្ងន់ធ្ងរ។ សារៈសំខាន់សំរាប់ដំណើរការនេះ គឺ ឆន្ទៈរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការគោរពការសន្យាផ្ទាល់របស់ខ្លួន ចំពោះការការពារជនភៀសខ្លួន ក្នុងការគោរពគោលការណ៍សំខាន់ស្តីពីការមិនបញ្ជូនត្រឡប់វិញ និងការទប់ទល់នឹងសម្ពាធពីខាងក្រៅពីប្រទេសនានាដែលមានអំណាចជាង ហើយថែមទាំង និងជាសំខាន់ផងនោះគឺប្រទេសទាំងឡាយរាប់ទាំងប្រទេសចិនផងដែរ ត្រូវគោរពការប្តេជ្ញាចិត្តតាមផ្លូវច្បាប់អន្តរជាតិរបស់កម្ពុជា ក្រោមអនុសញ្ញាទាំងឡាយដែលកម្ពុជាបានផ្តល់សច្ចាប័ន (អនុសញ្ញាស្តីពីជនភៀសខ្លួន អនុសញ្ញាប្រឆាំងទារុណកម្ម កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) ដើម្បីឲ្យប្រទេសទាំងនោះដកខ្លួនថយពីការដាក់សម្ពាធទៅលើប្រទេសតូចជាងខ្លួន ឲ្យប្រគល់មកឲ្យខ្លួន នូវបុគ្គលទាំងឡាយដែលអាចត្រូវការសិទ្ធិជ្រកកោន។

ការផ្លាស់ប្តូរគោលនយោបាយកាលពីសប្តាហ៍មុននេះ ធ្វើឲ្យអ្នកសុំសិទ្ធិជ្រកកោនពីប្រទេសចិនមានអារម្មណ៍គ្មានសុវត្ថិភាព ហើយថានឹងគ្មានសុវត្ថិភាពទេ សំរាប់ការនៅកម្ពុជាតទៅទៀត។

ការបញ្ជូនត្រឡប់វិញនេះ បានបង្កើតឲ្យមានទម្លាប់ជាអកុសលមួយ មិនមែនតែនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាអាចកើតមានទូលំទូលាយជាងនេះ។ យន្តហោះដែលបានចាកចេញទៅ កាលពីយប់ថ្ងៃសៅរ៍នេះ ពោរពេញដោយក្តីអាម៉ាស់ និងបង្ហាញថា សេរីភាពចាកផុតពីការខ្វះខាត និងការភ័យខ្លាច បានក្លាយជាតូចចង្អៀតថែមទៀត នៅក្នុងផ្នែកមួយនៃពិភពលោកនេះ”។